# ដើម្បីឱ្យបន្ទុករបស់អ្នកបានសំរាល

អែលឌើរ អិល វិតនី ក្លេតុន
ពីគណៈប្រធាននៃពួកចិតសិបនាក់

*បន្ទុកជួយទាំងឡាយផ្ដល់នូវឱកាសដើម្បីអនុវត្តរាល់គុណធម៌ដែលនាំឱ្យមានភាពឥតខ្ចោះ ។*

ជាច្រើនឆ្នាំមកហើយ នាព្រឹកព្រលឹមមួយ ខ្ញុំបានដើរនៅលើផ្លូវគ្រួសត្រង់មួយនៅទីក្រុងកាស្កូ ប្រទេសពេរូ នៅទីខ្ពស់លើភ្នំអង់ដេស ។ ខ្ញុំបានជួបបុរសក្នុងភូមិម្នាក់ ជាជនជាតិដើមភាគតិច បានដើរនៅលើផ្លូវមួយម្ដុំនោះដែរ ។ បុរសនោះ មានរូបរាងពុំសូវធំទេ ប៉ុន្តែគាត់បានលីបាវដែលមានដាក់អុសយ៉ាងច្រើនលើខ្នងគាត់ ។ បាវនោះធំស្មើរនឹងខ្លួនគាត់ ។ បាវដាក់អុសនោះ គឺមានទម្ងន់ប្រហាក់ប្រហែលនឹងគាត់ដែរ ។ គាត់បានចងវានឹងខ្សែពួរនៅពីក្រោមបាវ ហើយរុំជុំវិញថ្ងាស់របស់គាត់ ។ គាត់បានចងខ្សែពួរទាំងសងខាងនោះយ៉ាងជាប់នៅនឹងក្បាលគាត់ ។ គាត់បានដាក់ក្រណាត់មួយដុំនៅខាងក្រោមខ្សែពួរនៅពីលើក្បាលគាត់ ដើម្បីទ្រាប់កុំឱ្យឈើមុត ។ គាត់បានដើរទៅមុខជាមួយនឹងបន្ទុករបស់គាត់ ហើយបានបោះជំហានដោយប្រុងប្រយ័ត្ន និងលំបាក ។

បុរសនោះបានលីអុសទៅកាន់ផ្សារដើម្បីលក់ ។ ជាមធ្យមក្នុងមួយថ្ងៃគាត់ធ្វើដំណើរត្រឡប់ទៅវិញទៅមកពីរទៅបីដងកាត់ក្រុងដើម្បីជញ្ជូនអុសដ៏ធ្ងន់ៗនោះ ។

រូបភាពនៃការលំបាក ពេលដែលបុរសនោះត្រូវដើរឱនដើម្បីទ្រទ្រង់បន្ទុករបស់ខ្លួនផ្លូវ បានក្លាយជាការចងចាំដ៏មានអត្ថន័យបំផុតចំពោះខ្ញុំ ចាប់តាំងពីពេលនោះមកអស់រាំឆ្នាំ ។ តើគាត់នឹងអាចបន្តធ្វើការងារលីសែងដ៏ធ្ងន់បែបនេះដល់ពេលណាទៅ?

ជីវិតនេះបានដាក់បន្ទុកគ្រប់យ៉ាងលើយើងម្នាក់ៗ បន្ទុកខ្លះស្រាល ប៉ុន្តែបន្ទុកអ្នកដទៃទៀតធ្ងន់ និងឥតឈប់ឈរ ។ មនុស្សជួបភាពស្មុគស្មាញរាល់ថ្ងៃ ជាបន្ទុកដែលសាកល្បងសមត្ថភាពរបស់ពួកគេ ។ *ពួកយើង* ភាគច្រើនមានការពិបាក ពេលជួបនឹងបន្ទុកបែបនោះ ។ បន្ទុកនោះអាចជាទម្ងន់ខាងផ្លូវកាយ ឬផ្លូវចិត្ត ។ វាអាចជាទុក្ខព្រួយ ការជិះជាន់ និងការអស់កម្លាំង ។ ហើយវាក៏អាចបន្តកើតមានយ៉ាងយូរផងដែរ ។

នៅក្នុងទិដ្ឋភាពទូទៅ បន្ទុករបស់យើងកើតចេញពីប្រភពបីយ៉ាង ។ បន្ទុកមួយចំនួន គឺជាស្ថានភាពដែលកើតឡើងជាធម្មជាតិនៃពិភពលោកដែលយើងរស់នៅ ។ ជម្ងឺ ពិការភាព និងគ្រោះធម្មជាតិ ដូចជាគ្រោះរាំងស្ងួត ខ្យល់ព្យុះ រញ្ជួយផែនដីគឺកើតឡើងជារឿយៗ ទាំងយើងពុំបានធ្វើអ្វីខុសសោះ ។ យើងអាចរៀបចំខ្លួនសំរាប់គ្រោះធម្មជាតិនេះ ហើយមានពេលខ្លះ យើងអាចព្យាករណ៍ពីវាបាន ប៉ុន្តែនៅក្នុងលំនាំធម្មជាតិរបស់ជីវិត យើងទាំងអស់គ្នានឹងប្រឈមមុខចំពោះឧបសគ្គទាំងនេះមួយចំនួន ។

បន្ទុកផ្សេងទៀត គឺត្រូវបានដាក់មកលើយើង ដោយសារអ្នកដទៃបានប្រព្រឹត្តខុស ។ ការរំលោភបំពាន និងការញៀន និងភាពអត្តា-អាចធ្វើឱ្យយើងមានទ្រព្យសម្បត្តិគ្រប់យ៉ាង តែគ្រាន់តែជាស្ថានសួគ៌លើផែនដីប៉ុណ្ណោះ ចំពោះសមាជិកគ្រួសារដែលគ្មានកំហុស ។

អំពើបាប ទំនៀមទម្លាប់ខុសឆ្គង និគ្រោះ និងបទឧក្រិដ្ឋបានពង្រីកខ្លួននៅលើវិថីនៃជីវិត។ ទោះជាធ្វើអំពើបាបតិចតួច ដូចជាការធ្វេសប្រហែស អយុត្តិធម៌ និងចិត្តអាក្រក់ ក៏អាចធ្វើឱ្យអ្នកដទៃឈឺចាប់ និងវេទនាធ្ងន់ធ្ងរដែរ។

កំហុសផ្ទាល់ខ្លួន និងគុណវិបត្តិរបស់យើងបានបង្កបញ្ហាជាច្រើនដល់យើង និងអាចដាក់បន្ទុកដ៏ធ្ងន់នៅលើស្មារបស់យើងផ្ទាល់។ បន្ទុកដែលពិបាកបំផុតដែលយើងដាក់លើខ្លួនរបស់យើងគឺជាបន្ទុកនៃអំពើបាប។ យើងទាំងអស់គ្នាបានស្គាល់ពីវិប្បដិសារី និងការឈឺចាប់ដែលកើតឡើងដោយពុំអាចជៀសរួច នៅពេលយើងពុំបានធ្វើតាមព្រះបញ្ញត្តិទាំងឡាយ។

មិនថាយើងប្រឈមមុខនឹងបន្ទុកលក្ខណៈណាក្នុងជីវិត ដែលជាលទ្ធផលនៃស្ថានភាពធម្មជាតិ ដូចជាកិរិយាមិនត្រឹមត្រូវរបស់អ្នកដទៃ ឬជាកំហុសផ្ទាល់ខ្លួន និងគុណវិបត្តិទាំងឡាយរបស់យើងនោះទេ យើងទាំងអស់គ្នាគឺជាកូនចៅរបស់ព្រះវរបិតាសួគ៌ ដែលបានបញ្ជូនយើងមកលើ ផែនដីជាផ្នែកមួយនៃផែនការដ៏នៅអស់កល្បជានិច្ចរបស់ទ្រង់ ដើម្បីឱ្យយើងបានរីកចំរើន និងលូតលាស់។ បទពិសោធន៍ដ៏ពិសេសរបស់យើងម្នាក់ៗអាចជួយរៀបចំ ឱ្យត្រឡប់ទៅរកទ្រង់ វិញ។ ភាពទីទាល់ និងទុក្ខវេទនាដែលយើងជួបប្រទះ ទោះជាវាលំបាកនឹងស៊ូទ្រាំ តែនៅបំផុត ទស្សនវិស័យមកពីសួគ៌ានឹងលើកឡើងថា ត្បិត "គ្រាន់តែមួយភ្លែតប៉ុណ្ណោះទេ ហើយខណៈនោះ បើសិនជា [យើង] ស៊ូទ្រាំការណ៍នោះដោយហ្មត់ចត់ នោះព្រះទ្រង់ ដំកើង [យើង] ឡើងនៅស្ថានខ្ពស់"។ 1 យើងត្រូវតែខិតខំឱ្យអស់ពីសមត្ថភាពដើម្បីស៊ូទ្រាំនឹងបន្ទុករបស់យើង "ឱ្យបានល្អ" ដរាបណាវាមាន "មួយភ្លែតប៉ុណ្ណោះ" ក្នុងការស៊ូទ្រាំនឹងបន្ទុកទាំងនោះ។

បន្ទុកជួយផ្តល់ឱកាសដើម្បីអនុវត្តគុណធម៌ដែលនាំឱ្យមានភាពឥតខ្ចោះ។ បន្ទុករបស់យើងដឹកនាំយើងទៅ "នាំមកសេចក្តីទូន្មាននៃព្រះវិញ្ញាណ និង [បោះបង់ចោល] ភាពជាមនុស្សខាងសាច់ឈាមចេញ ហើយ [ក្លាយទៅជា] អ្នកបរិសុទ្ធវិញតាមរយៈដង្វាយធួននៃព្រះគ្រីស្ទដ៏ជាព្រះអម្ចាស់ ហើយក្លាយទៅដូចជាកូនក្មេង ងាយប្រដៅ ស្លូតបូត ទាបរាបសា អត់ឱន ពោរពេញទៅដោយសេចក្តីស្រឡាញ់ ព្រមទទួលនូវអ្វីៗទាំងអស់ ដែលព្រះអម្ចាស់ទ្រង់ទតឃើញថាល្អ ដូចជា [យើង] ព្រមធ្វើតាមឪពុកខ្លួនដូច្នោះ"។2 ហេតុដូច្នោះហើយ បន្ទុកទាំងនេះបានក្លាយជាពរជ័យ ទោះបីជាញឹកញាប់ ពរជ័យទាំងនោះលាក់កំបាំង ហើយអាចតម្រូវពេលវេលាច្រើន ការប្រឹងប្រែង និងសេចក្តីជំនឿដើម្បីទទួលយក និងយល់ដឹងក្តី។ ឧទាហរណ៍ចំនួនបួនអាចជួយពន្យល់ពីបន្ទុកនេះ:

ទីមួយ អាដាម ត្រូវបានប្រាប់ថា "ដីត្រូវបណ្តាសាដោយព្រោះអ្នក" ដែលមានន័យថា ជាប្រយោជន៍ដល់គាត់ "បានអាហារបរិភោគដោយការបែកញើស"។ 3 កិច្ចការគឺជាបន្ទុកដែលមានជាបន្ត ប៉ុន្តែវាក៏ជាពរជ័យដែលមានជាបន្តដែរ "ដោយព្រោះ [យើង] " ត្បិតបន្ទុកទាំងឡាយបង្រៀន*យើង* នូវមេរៀនដែលយើងអាចរៀនតែប៉ុណ្ណោះ "ដោយការ[យើង]បែកញើស"។

ទីពីរ អាលម៉ា បានមើលឃើញថា ភាពទីទាល់ក្រ និង "ការទុក្ខវេទនា [ពួកជនក្រីក្រនៅក្នុងពួកសូរាំ] បានធ្វើ ឱ្យគេបន្ទាបខ្លួន ហើយពួកគេកំពុងប្រុងប្រៀបនឹងស្តាប់ព្រះបន្ទូល"។4 លោកបានបន្ថែមទៀតថា "ពីព្រោះអ្នកត្រូវគេបង្ខំឱ្យមានចិត្តសុភាពរាបសា នោះអ្នករាល់គ្នាមានពរហើយ"។5 បញ្ហាសេដ្ឋកិច្ចបច្ចុប្បន្នរបស់យើង អាចជួយរៀបចំយើងឱ្យស្តាប់ព្រះបន្ទូលរបស់ព្រះអម្ចាស់ ក៏ដូចជាប្រទានពរជ័យដល់យើងក្នុងទំរង់ដូចគ្នាផងដែរ។

ទីបី ពីព្រោះតែ "*រយៈពេលយូរក្រៃលែងនៃសង្គ្រាម [របស់ពួកគេ]*" ពួកសាសន៍នីហ្វៃ និងលេមិនជាច្រើន "មានចិត្តទន់ភ្លន់ មកពីសេចក្តីវេទនាទាំងឡាយរបស់គេ ដរាបដល់ពួកគេបានបន្ទាបខ្លួននៅចំពោះព្រះ គឺនៅក្នុងជំរៅ នៃភាពទន់ទាប"។ 6 បញ្ហាខាងផ្នែកនយោបាយ កង្វះសណ្តាប់ធ្នាប់សង្គម និងចលាចលខាងវប្បធម៌ ឬនៅជ្រុងម្ខាងទៀតនៃពិភពលោកពួកចោរកាឌីអានតុនសម័យទំនើបអាចធ្វើឱ្យយើងមានចិត្តរាបសា និងជំរុញចិត្តយើងឱ្យស្វែងជំរកសួគ៌ា ជាជំរកជ្រកពីបញ្ហាខាងសង្គមទាំងឡាយ។

ទីបួន យ៉ូសែប ស្ម៊ីធ ត្រូវបានប្រាប់ថា ហេតុការណ៍ដ៏អាក្រក់ដែលលោកបានទទួលរងអស់ជាច្រើនឆ្នាំ ក្រោមដៃមាសត្រូវរបស់លោកបាន"ផ្តល់ការពិសោធន៍ដល់ [លោក] ហើយ...ទៅជាការល្អ[សំរាប់លោក]"។7 ទុក្ខសោកដែល យើងទទួលរងដោយទង្វើរធ្វើឱ្យអាក់អន់ចិត្តពីអ្នកដទៃគឺមានតម្លៃណាស់ និងឈឺចាប់ ជាមជ្ឈមណ្ឌលសំរាប់ការអភិវឌ្ឍន៏អប្បកិរិយារបស់យើងផ្ទាល់។

លើសពីនោះទៅទៀត ការស៊ូទ្រាំនឹងបន្ទុករបស់យើង អាចធ្វើឱ្យយើងចេះអត់ទ្រាំនឹងបញ្ហាអ្នកដទៃបង្កឡើង។ សាវកប៉ុលបានបង្រៀនថា យើងគួរតែ "...យកអាសាគ្នាទៅវិញទៅមក យ៉ាងនោះទើបបានសំរេចតាមក្រិត្យវិន័យនៃព្រះគ្រីស្ទ"។ 8 យោងទៅតាមសេចក្តីសញ្ញានៃពិធីបុណ្យជ្រមុជទឹករបស់យើង សេចក្តីសញ្ញាពិធីបុណ្យជ្រមុជទឹកតម្រូវឱ្យយើងគួរតែ "ទទួលបន្ទុកគ្នាទៅវិញទៅមក ដើម្បីឱ្យបន្ទុកនោះបានស្រាល មែនហើយ ហើយ[នឹង]ព្រមទួញយំជាមួយនឹង អ្នកណាដែលទួញយំ មែនហើយ ហើយកំសាន្តទុក្ខដល់អស់អ្នកដែលកំពុងត្រូវការកំសាន្តទុក្ខ"។9

ការរក្សាសេចក្តីសញ្ញាក្នុងពិធីបុណ្យជ្រមុជទឹករបស់យើង ជួយសំរាលដល់បន្ទុក *របស់យើង* ក៏ដូចជាបន្ទុកនៃជនទាំងឡាយណាដែលយើងបំរើផងដែរ។10 ជនទាំងឡាយណាដែលផ្តល់ចំពោះជំនួយបែបនេះដល់អ្នកដទៃនឹងឈរនៅដីបរិសុទ្ធ។ នៅក្នុងការពន្យល់អំពីបញ្ហានេះ ព្រះអម្ចាស់បានបង្រៀនថាៈ

"តើខ្ញុំបានឃើញទ្រង់ស្រេកឃ្លាន ហើយបានថ្វាយទ្រង់សោយពីកាលណា? ឬស្រេក ហើយបានឱ្យទ្រង់ផឹកពីកាលណា?

"តើយើងខ្ញុំបានឃើញទ្រង់ជាអ្នកដទៃ ហើយបានទទួលទ្រង់ពីកាលណា ឬទ្រង់អាក្រាត ហើយបានបំពាក់ថ្វាយទ្រង់ពីកាលណា?

"តើយើងខ្ញុំបានឃើញទ្រង់ ឈឺ ឬជាប់គុក ហើយបានមកទ្រង់ពីកាលណា?

"នោះស្តេចនឹងឆ្លើយទៅគេថា យើងប្រាប់អ្នករាល់គ្នាជាប្រាកដថា អ្នករាល់គ្នាបានធ្វើការទាំងនោះ ដល់អ្នកតូចបំផុតក្នុងពួកបងប្អូនយើងនេះ នោះឈ្មោះថា បាន *ធ្វើ* ដល់យើងដែរ"។11

តាមរយៈបន្ទុកទាំងនេះ ព្រះអង្គសង្គ្រោះបានប្រទានដល់យើងនូវការគាំទ្រ និងការឧបត្ថម្ភដល់យើង ហើយតាម ពេលវេលានិងវិធីរបស់ទ្រង់ ទ្រង់បានប្រទានការរំដោះ។ នៅពេលដែលអាលម៉ា ហើយគ្នីគ្នារបស់គាត់បានរត់គេចពីពួកសត្រូវរបស់ស្តេចណូអេ ពួកគេបានបង្កើតសហគមមួយ ដែលបានដាក់ឈ្មោះថាដែនដីហេឡាម។ ពួកគេបានចាប់ ផ្តើមភ្ជួរដី ហើយចាប់ផ្តើមសង់អគារទាំងឡាយ មែនហើយពួកគេបានកើនឡើង ហើយបានរីកចំរើនឡើង។ 12 ដោយពុំមានការព្រមានជាមុន ពួកសត្រូវ

សាសន៍លេមិន បានដាក់បន្ទុកលើពួកគេហើយ "គ្មានអ្នកណាម្នាក់អាចដោះពួកគេបានឡើយ លើកលែងតែព្រះអម្ចាស់ជាព្រះរបស់គេប៉ុណ្ណោះ"។ 13 ទោះជាយ៉ាងណាក្តី ការរំដោះនោះពុំកើតឡើងភ្លាមៗនោះទេ។

ពួកសត្រូវរបស់ពួកគេបានចាប់ផ្តើម "អនុវត្តសិទ្ធិអំណាចទៅលើពួកគេ"។14 ទោះបីជាពួកគេត្រូវបាន គំរាមគំហែងដល់ស្លាប់ដោយសារតែការអធិស្ឋាន 15 ក៏អាលម៉ា និង ប្រជារាស្ត្ររបស់លោក "បានបន្លឺសម្លេងអំពាវនាវ ដល់ព្រះអម្ចាស់ជា [ព្រះ] ហើយទ្រង់បានជ្រាបនូវគំនិតដែលនៅក្នុងចិត្តគេ"។ 16 ដោយសារតែសេចក្តីល្អ និង ការគោរពប្រតិបត្តិតាមសេចក្តីសញ្ញានៃពិធីបុណ្យជ្រមុជទឹករបស់ពួកគេ ពួកគេត្រូវបានរំដោះ ឱ្យរួចពីទាសភាព។ ព្រះអម្ចាស់បានមានព្រះបន្ទូលទៅកាន់ពួកគេថា:

"យើងនឹងសំរាលបន្ទុកទាំងឡាយដែលដាក់នៅលើស្មាអ្នកផង... ហើយសូម្បីតែរូបអ្នកក៏នឹងមិនអាចចាប់អារម្មណ៍ថា មានបន្ទុកទាំងនោះនៅលើខ្នងអ្នកឡើយ ទោះនៅពេលអ្នកជាប់នៅក្នុងសេវកភាពក្តី ហើយយើងនឹងធ្វើការនេះ ដើម្បីឱ្យអ្នករាល់គ្នាអាចឈរជាសាក្សីដល់យើងពីអំណឹះតទៅ ហើយដើម្បីឱ្យអ្នករាល់គ្នាអាចដឹងជាពិតប្រាកដថា យើងជាព្រះអម្ចាស់ដ៏ជាព្រះមករករាស្ត្រយើងក្នុងពេលគេស្ថិតក្នុងសេចក្តីវេទនា។

"ហើយឥឡូវនេះ ហេតុការណ៍បានកើតឡើងថា បន្ទុកទាំងឡាយដែលដាក់នៅលើអាលម៉ា និងបងប្អូនលោក ត្រូវបានសំរាលទៅមែនហើយ ព្រះអម្ចាស់ទ្រង់បានចំរើនកម្លាំងឱ្យគេ ដើម្បីឱ្យគេអាចទ្រាំបន្ទុកទាំងឡាយរបស់គេ បានដោយងាយ ហើយពួកគេបានធ្វើតាមអស់ទាំងព្រះហឫទ័យនៃព្រះអម្ចាស់ ដោយការរីករាយ និងដោយការអត់ធន់។

"ហើយហេតុការណ៍បានកើតឡើងថា សេចក្តីជំនឿ និងសេចក្តីអត់ធន់របស់គេមានទំហំធំ រហូតដល់សម្លេងនៃ ព្រះអម្ចាស់បានបន្លឺមកគេទៀតថា: ចូរក្សាន្តចិត្តចុះ ព្រោះថ្ងៃស្អែក យើងនឹងដោះអ្នកឱ្យរួចផុតពីសេវកភាពហើយ"។18

ព្រះរាជបុត្រានៃព្រះបានប្រទានឱ្យយើងដោយសប្បុរធម៌នូវការរំដោះចេញពីសេវកភាពនៃអំពើបាបរបស់យើង ក៏ដូចបន្ទុកដ៏ធ្ងន់បំផុតដែលយើងទទួលរងផងដែរ។ នៅក្នុងការធ្វើដង្វាយធួនរបស់ទ្រង់ ទ្រង់បានទទួលរងនូវការឈឺចាប់ "ស្របតាមសាច់ឈាមដើម្បីទ្រង់អាចយកដាក់លើរូបអង្គទ្រង់ នូវអំពើបាបទាំងឡាយរបស់រាស្ត្រទ្រង់ ដើម្បីទ្រង់អាចលុបចោល នូវអំពើរំលងទាំងឡាយរបស់គេ ស្របតាមព្រះចេស្តារការដោះលែងរបស់ទ្រង់"។19 ព្រះគ្រីស្ទ "បានរងទុក្ខនូវការទាំងនេះ ជំនួសមនុស្សទាំងអស់ ដើម្បីកុំឱ្យគេអាចរងទុក្ខ បើសិនជាពួកគេប្រែចិត្ត"។20 នៅពេលដែលយើងប្រែចិត្ត ហើយគោរពតាមព្រះបញ្ញត្តិទាំងឡាយ ធ្វើឱ្យខ្លួនយើងបានធូរស្រាលពីបន្ទុកនៅក្នុងមនសិការរបស់យើង ដែលកើតមានឡើងរួមជាមួយនឹងជំនួយមកពីតែព្រះអង្គសង្គ្រោះប៉ុណ្ណោះ ត្បិត "ប្រាកដណាស់ថា អស់អ្នកណាដែលប្រែចិត្ត នោះនឹងបានសេចក្តីមេត្តាករុណា"។21

ខ្ញុំចងចាំអំពីបុរសនៅប្រទេសពេរ៉ូ ម្នាក់នោះដែលបានលីបាវអុសដ៏ធ្ងន់នៅលើខ្នងរបស់គាត់ដោយលំបាក។ ចំពោះខ្ញុំ បុរសរូបនោះគឺជា រូបភាពរបស់យើងទាំងអស់គ្នា នៅពេលដែលយើងស្មុគស្មាញនឹងបន្ទុកនៃជីវិត។ ខ្ញុំដឹងថា បើយើងគោរពតាមព្រះបញ្ញត្តិទាំងឡាយនៃព្រះ និងសេចក្តីសញ្ញា របស់យើង នោះទ្រង់នឹងជួយសំរាលបន្ទុករបស់យើង។ ទ្រង់នឹងពង្រឹងយើង។ នៅពេលយើងប្រែចិត្ត នោះទ្រង់នឹងអភ័យទោសដល់យើង ហើយប្រទានពរជ័យដល់យើងនូវសេចក្តីសុខសាន្តក្នុងសតិសម្បជញ្ញៈ និងសេចក្តី-

អំណរ ។22 សុំឱ្យយើងទទួលយកភាពរីករាយ និងដោយចិត្តអំណត់តាមព្រះឆន្ទៈរបស់ព្រះអម្ចាស់ទាំងអស់ ខ្ញុំសូមអធិស្ឋាននៅក្នុងនាមនៃព្រះយេស៊ូវគ្រីស្ទ អាម៉ែន ។

កំណត់ចំណាំ

1. គ. និង ស. 121:7--8 ។
2. ម៉ូសាយ 3:19 ។
3. ម៉ូសេ 4:23, 25 ។
4. អាលម៉ា 32:6 ។
5. អាលម៉ា 32:13 ។
6. អាលម៉ា 62:41 ។
7. គ. និង ស. 122:7 ។
8. កាឡាទី 6:2 ។
9. ម៉ូសាយ 18:8--9 ។
10. សូមមើល ម៉ាថាយ 10:39, 11:28--30 ម៉ូសាយ 2:22 ។
11. សូមមើល ម៉ាថាយ 25:35--40 ។
12. សូមមើល ម៉ូសាយ 23:5, 19--20 ។
13. សូមមើល ម៉ូសាយ 23:23--26 ។
14. ម៉ូសាយ 24:9 ។
15. សូមមើល ម៉ូសាយ 24:10--11 ។
16. ម៉ូសាយ 24:12 ។
17. សូមមើល ម៉ូសាយ 18:8--10, 24:13 ។
18. ម៉ូសាយ 24:14--16 ។
19. អាលម៉ា 7:13 ។
20. គ. និង ស. 19:16 ។
21. អាលម៉ា 32:13 ។
22. សូមមើល ម៉ូសាយ 4:3 អាលម៉ា 36:19-21 ។